ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៣ អនក្រ

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

កំណត់របៀបរបបការងារនិងបែងចែកភារកិច្ចជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម។

**ប្រការ២ .-**

នាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំការងាររួមរបស់គណៈរដ្ឋមន្ត្រីនិងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ។

**ប្រការ៣ .-**

ឧបនាយករដ្ឋមន្ត្រី៖

១- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រីអវត្តមាន ជួយនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននិងការជួញដូរមនុស្ស ការដឹកនាំប្រតិបត្តិការទប់ស្កាត់និងប្រឆាំងភេរវកម្ម ការងារគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងការបំផ្លាញចោលអាវុធ ព្រមទាំងការងារភូមិឃុំមានសុវត្ថិភាព ការងារក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងការងារផ្សេងៗទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាអង្គភាពពិសេសប្រឆាំងភេរវកម្ម ក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន។

៣- ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកផ្តល់យោបល់ជូននាយករដ្ឋមន្ត្រីអំពីក្របខ័ណ្ឌគោលនយោបាយក្រៅប្រទេស ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យនិងសម្រេចលើសំណើសុំកូនការសុំលាសញ្ជាតិ និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៤- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារអធិការកិច្ចនិងសវនកម្ម ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារសង្គម។

៥- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ សម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដាន សម្របសម្រួលដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ដឹកនាំផ្ទាល់ក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រីក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៩៦នៃរដ្ឋធម្មនុញ្ញ ដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យនិងសម្រេចលើការងាររបស់«ច្រកចេញចូលតែមួយ»នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានវិទយិតភាពខ្ពស់ ដែលតម្រូវឱ្យសុំការណែនាំឬការសម្រេចពីនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារបង្ការ ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ។

៦- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៧- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការងារពិសេសផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៨- ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការបរទេស ការសម្របសម្រួលការបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការងារពិសេសផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៩- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១០- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

**ប្រការ៤ .–**

នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រីស្តីទី។

**ប្រការ៥ .-**

ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកអនុវត្តការងារឬបេសកកម្មផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា៣០នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

**ប្រការ៦ .-**

ឧបនាយករដ្ឋមន្ត្រី១រូបៗមានទីប្រឹក្សាចំនួន៤រូប ក្នុងនោះ ២រូបមានឋានៈស្មើរដ្ឋលេខាធិការ ២រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងជំនួយការចំនួន៥រូប ក្នុងនោះ ១រូបមានឋានៈស្មើអគ្គនាយក ២រូបមានឋានៈស្មើអគ្គនាយករង និង ២រូបមានឋានៈស្មើប្រធាននាយកដ្ឋាន។

**ប្រការ៧ .-**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស៖

១- ឯកឧត្តម **ម៉ុល សារឿន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដោយរួមការងារជាមួយសម្តេចពិជ័យសេនា **ទៀ បាញ់** និងឯកឧត្តម **ប្រាក់ សុខុន** ការងារស្វែងរកអដ្ឋិធាតុយុទ្ធជនអាមេរិកនិងវៀតណាម និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២- ឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអតីតយុទ្ធជននិងជនពិការ ទទួលបន្ទុកជាអនុប្រធានទី១នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៣- ឯកឧត្តម **មាស សុផា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការមីននិងគ្រាប់មិនទាន់ផ្ទុះ ការងារវិស្វកម្មកងយោធពលខេមរភូមិន្ទ និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៤- ឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រាជរដ្ឋាភិបាលនិងអង្គភាពប្រឆាំងអំពើពុករលួយ។

៥- ឯកឧត្តម **អៀង ម៉ូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។

៦- ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន។

៧- ឯកឧត្តម **យឹម ឆៃលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

៨- ឯកឧត្តម **ជិន ម៉ិនសាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៩- ឯកឧត្តម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជានាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១០- ឯកឧត្តម **ឃុន ហាំង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានប្រចាំការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

១១- ឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិអេស្កាប់និងជាអនុប្រធានទី១នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន។

១២- ឯកឧត្តម **អូស្មាន ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារចលនាមូស្លីម និងការងារផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

**ប្រការ៨ .-**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៩ .-**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស១រូបៗមានជំនួយការចំនួន៥រូប ក្នុងនោះ ២រូបមានឋានៈស្មើអគ្គនាយក ១រូបមានឋានៈស្មើអគ្គនាយករង និង២រូបមានឋានៈស្មើប្រធាននាយកដ្ឋាន។

**ប្រការ១០ .-**

សេចក្តីសម្រេចលេខ៥០ សសរ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .-**

នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១១
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ